# សេចក្តីថ្លែងការណ៍របស់សហភាពអឺរ៉ុបក្នុងស្រុកស្តីពី
# ស្ថានភាពនយោបាយនៅក្នុងប្រទេសកម្ពុជា

ដោយមានឯកភាពជាមួយប្រមុខបេសកកម្មការទូតរបស់សហភាពអឺរ៉ុបនៅក្នុងប្រទេសកម្ពុជា ប្រតិភូសហភាពអឺរ៉ុប សូមចេញនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម៖

ប្រមុខបេសកកម្មការទូតនៃសហភាពអឺរ៉ុបនៅរាជធានីភ្នំពេញ សូមសំដែងនូវការសោកស្តាយយ៉ាងខ្លាំងចំពោះការកើនឡើងកំដៅនយោបាយប្រកបដោយភាពគ្រោះថ្នាក់ក្នុងរយៈពេលប៉ុន្មានថ្ងៃថ្មីៗនេះ និងអំពាវនាវ សូមអោយបញ្ឈប់ការយាយីតាមផ្លូវតុលាការចំពោះមេដឹកនាំស្តីទីនៃគណបក្សប្រឆាំង និងតំណាងអង្គការសង្គមស៊ីវិល។ យើងសូមជំរុញអោយអាជ្ញាធរកម្ពុជា វិលមករកការចចារជាមួយគណបក្សប្រឆាំង ក្នុងន័យស្ថាបនានិងដោយសន្តិវិធីអោយបានឆាប់តាមដែលអាចធ្វើទៅបាន ដែលយើងយល់ឃើញថាជាលក្ខខណ្ឌជាមុន ដើម្បីភាពស្របច្បាប់ នៃការបោះឆ្នោតនាពេលខាងមុខ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០១៦